វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺៈ

- សហភាពអឺរ៉ុបអនុម័តទឹកប្រាក់ ១១២លានអឺរ៉ូ សម្រាប់ជួយជម្រុញដល់វិស័យជលផលកម្ពុជា
- គោលនយោបាយបន្ធូរបន្ថយរូបិយវត្ថុ បង្កការភ្ញាក់ផ្អើលបន្ថែមទៀតនៅអាស៊ី ដោយសារប្រទេសឥណ្ឌូនេស៊ីកាត់បន្ថយអត្រាការប្រាក់
- ការយកពន្ធគយរបស់លោកត្រាំនឹងប៉ះពាល់ដល់ចំណូលគ្រួសារនីមួយៗចំនួន $៦០០ គិតត្រឹមឆ្នាំ២០២០

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះគឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីអោយការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះមានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តន៍នៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### សហភាពអឺរ៉ុបអនុម័តទឹកប្រាក់ ១១២លានអឺរ៉ូ សម្រាប់ជួយជម្រុញដល់វិស័យជលផល

សហភាពអឺរ៉ុប សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុម័តទៅលើកម្មវិធីថ្មីមួយ ដែលគាំទ្រដល់កំណើនដែលប្រកបដោយចីរភាព និងបរិយាប័ន្ននៃវិស័យជលផលរបស់កម្ពុជា។ កម្មវិធីជំនួយនេះ គឺជាសកម្មភាពធំបំផុតដែលគាំទ្រដោយមូលនិធិសហភាពអឺរ៉ុបនៅកម្ពុជា ដែលមានទឹកប្រាក់ប្រមាណ ១១២ លានអឺរ៉ូ (ប្រមាណ១២៥ លានដុល្លារ) សម្រាប់ឆ្នាំ២០១៩-២០២៣។

គោលដៅរបស់កម្មវិធីនេះ គឺដើម្បីបង្កើនសន្តិសុខស្បៀងអាហារ លើកកម្ពស់អាហាររូបត្ថម្ភឲ្យកាន់តែប្រសើរ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។ កម្មវិធីនេះបែងចែកជាសកម្មភាពពីរធំៗដែលបំពេញឲ្យគ្នាទៅវិញទៅមក គឺៈ ការអភិវឌ្ឍប្រកបដោយចីរភាពទៅលើផ្នែកគ្រប់គ្រងធនធានជលផល (៨៧ លានអឺរ៉ូ) និងផ្នែកវារីវប្បកម្ម (២៥ លានអឺរ៉ូ)។

កិច្ចប្រឹងប្រែងរួមគ្នារវាងសហភាពអឺរ៉ុប និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នឹងផ្តល់នូវអត្ថប្រយោជន៍ទាំងរយៈពេលខ្លី និងរយៈពេលវែងទៅដល់កសិករ វិស័យឯកជន និងអ្នកប្រើប្រាស់។ បើយោងតាមប្រសាសន៍ឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ "រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ពីតួនាទីដ៏សំខាន់របស់វិស័យជលផល ក្នុងការចូលរួមចំណែកអភិវឌ្ឍប្រទេសកម្ពុជា ហើយរាជរដ្ឋាភិបាល ក៏បានខិតខំប្រឹងប្រែងដើម្បីឲ្យប្រជាជនកម្ពុជាគ្រប់រូបទទួលបានជីវភាពរស់នៅល្អប្រសើរជាងមុន និងបន្តទទួលបាននូវរសជាតិពិសេសរបស់ត្រីមឹក បង្គា និងក្តាម ពីទឹកសាប និងទឹកសមុទ្ររបស់ប្រទេសកម្ពុជា។

## តារាងប្រចាំសប្តាហ៍៖ សន្ទស្សន៍សន្តិភាពពិភពលោក ឆ្នាំ២០១៩

តារាងសប្តាហ៍នេះធ្វើការប្រៀបធៀបចំណាត់ថ្នាក់របស់បណ្តាប្រទេសក្នុងសមាគមន៍អាស៊ាន នៅក្នុងសន្ទស្សន៍សន្តិភាពជាសកល (GPI) នៅក្នុងឆ្នាំ២០១៩ ដែលរៀបចំឡើងដោយវិទ្យាស្ថានសេដ្ឋកិច្ច និងសន្តិភាព ឆ្នាំ២០១៩។

**សន្ទស្សន៍សន្តិភាពជាសកល ឆ្នាំ២០១៩**




ប្រភព៖ វិទ្យាស្ថានសេដ្ឋកិច្ច និងសន្តិភាព (pdf)

សន្ទស្សន៍សន្តិភាពជាសកល វាស់វែងពីកម្រិតនៃស្ថានភាពសន្តិភាពរបស់រដ្ឋ ឬតំបន់ឯករាជ្យមួយ ដោយប្រើប្រាស់មាត្រដ្ឋានពី១ ទៅ៥ (ពិន្ទុកាន់តែតូច កាន់តែប្រសើរ)។ សន្ទស្សន៍នេះផ្តល់ចំណាត់ថ្នាក់ទៅដល់រដ្ឋ ឬប្រទេសចំនួន ១៦៣ តាមរយៈការវាស់វែងទៅលើសូចនាករគុណភាព និងបរិមាណចំនួន ២៣ នៅក្នុងដែនវិស័យធំបីរួមមាន៖ កម្រិតនៃសុវត្ថិភាព និងសន្តិសុខសង្គម, វិសាលភាពនៃជម្លោះក្នុងស្រុក និងអន្តរជាតិ, និងកម្រិតនៃយោធា។

នៅក្នុងឆ្នាំ២០១៩ ប្រទេសសឹង្ហបុរី ស្ថិតនៅចំណាត់ថ្នាក់ទី៧ ក្នុងចំនោមប្រទេសនៅក្នុងសាកលលោក និងជាប្រទេសដែលមានសន្តិភាពជាងគេនៅក្នុងអាស៊ាន ស្របពេលដែលប្រទេសម៉ាឡេស៊ីស្ថិតនៅពីក្រោយ (ចំណាត់ថ្នាក់ទី១៦)។ ប្រទេសឥណ្ឌូនេស៊ី (ទី៤១) ប្រទេសឡាវ (ទី៤៥) ប្រទេសវៀតណាម (ទី៥៧) និងប្រទេសកម្ពុជា (ទី៨៩) គឺស្ថិតនៅចំណោមជួរកណ្តាល។ រីឯប្រទេសដែលមានសន្តិភាពតិចបំផុតនៅក្នុងអាស៊ាន គឺប្រទេសថៃ (ចំណាត់ថ្នាក់ទី១១៦), ប្រទេសមីយ៉ាន់ម៉ា (ទី១២៥) និងប្រទេសហ្វីលីពីន (ទី១៣៤)។

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## គោលនយោបាយបន្ធូរបន្ថយរូបិយវត្ថុ បង្កការភ្ញាក់ផ្អើលបន្ថែមទៀតនៅក្នុងអាស៊ី ដោយសារប្រទេសឥណ្ឌូនេស៊ីកាត់បន្ថយអត្រាការប្រាក់

ធនាគារកណ្តាលមួយទៀត បានចូលរួមធ្វើគោលនយោបាយ បន្ធូរបន្ថយរូបិយវត្ថុ នៅក្នុងអាស៊ីនាសប្តាហ៍នេះ។ ធនាគារកណ្តាលរបស់ឥណ្ឌូនេស៊ីបានកាត់បន្ថយអត្រាការប្រាក់របស់ខ្លួនចំនួន ២៥ ពិន្ទុមូលដ្ឋាន (basis point) មកត្រឹម ៥,៥% ដើម្បីគាំទ្រកំណើនក្នុងអំឡុងពេលដែលសេដ្ឋកិច្ចមានភាពផុយស្រួយ ដោយសារតែជម្លោះពាណិជ្ជកម្មរវាងចិន និង អាមេរិក។

ការកាត់អត្រាការប្រាក់នេះមិនត្រូវបានគេរំពឹងទុកមុនទេ ព្រោះបើយោងតាមការស្ទង់មតិដោយ សារព័ត៌មានReuters ក្នុងចំនោមសេដ្ឋវិទូ១៩រូប ដែលក្នុងនោះមាន១៧រូបរំពឹងថាធនាគារនឹងរក្សាអត្រាការប្រាក់នៅដដែល ក្នុងខែសីហា (CNBC)។

ធនាគារកណ្តាលមួយចំនួន ដែលរួមមាន ម៉ាឡេស៊ី ហ្វីលីពីន ថៃ និងកូរ៉េខាងត្បូង ទើបតែធ្វើការកាត់បន្ថយអត្រាការប្រាក់ នាពេលថ្មីៗនេះ។ ទោះជាយ៉ាងណាក៏ដោយ ការកាត់បន្ថយអត្រាការប្រាក់របស់ឥណ្ឌូនេស៊ី ទំនងមិនមែនជាប្រទេសចុងក្រោយឡើយ សេដ្ឋវិទូមួយចំនួនរំពឹងថា អាចនឹងមានប្រទេសផ្សេងៗទៀតនឹងធ្វើដូច្នេះដែរ ដូចជា ប្រទេសសឹង្ហបុរីជាដើម។

# សេដ្ឋកិច្ចពិភពលោក

## ការយកពន្ធគយរបស់លោកត្រាំ នឹងប៉ះពាល់ដល់ចំណូលគ្រួសារនីមួយៗចំនួន $៦០០ គិតត្រឹមឆ្នាំ២០២០

យោងទៅតាមទស្សនវិស័យថវិកា និងសេដ្ឋកិច្ចចុងក្រោយ ដែលធ្វើឡើងដោយការិយាល័យថវិកាសភាអាមេរិក(CBO) បានបង្ហាញថា នៅឆ្នាំ២០២០ ចំណូលពិតប្រចាំឆ្នាំរបស់គ្រួសារនៅអាមេរិកនឹងបាត់បង់ប្រមាណ ៦០០ដុល្លារ ដោយសារពន្ធគយដែលអនុវត្តដោយរដ្ឋបាលលោកត្រាំ (pdf)។ ចំនួនប៉ាន់ស្មាននេះ

មិនបានរួមបញ្ចូលនូវពន្ធគយបន្ថែមដែលគ្រោងនឹងអនុវត្តនៅក្នុងខែកញ្ញា និងខែធ្នូនៅឡើយទេ។

ការិយាល័យថវិកាសភា បានប៉ាន់ប្រមាណថា គោលនយោបាយពន្ធគយ នឹងបណ្តាលឲ្យមានការខាតបង់សកម្មភាពសេដ្ឋកិច្ច ដែលមានតម្លៃប្រហែល ៦០ប៊ីលានដុល្លារ ដែលស្មើនឹងការធ្លាក់ចុះ ០,៣%នៃកំណើន ផ.ស.ស.។

របាយការណ៍នេះក៏បានព្យាករណ៍ថា ឱនភាពថវិការបស់អាមេរិកនឹងឈានទៅដល់ ៩៦០ ប៊ីលានដុល្លារ ហើយនិងកើនឡើងដល់ប្រមាណ ១,២ ទ្រីលានដុល្លារជាមធ្យម ក្នុងអំឡុងឆ្នាំ២០២០ ដល់ឆ្នាំ២០២៩។ បំណុលសហព័ន្ធក៏ត្រូវបានរំពឹងថានឹងអាចឈានទៅកម្រិតខ្ពស់បំផុត បន្ទាប់ពីសង្គ្រាមលោកលើកទី២ គឺពី៧៩% ក្នុងឆ្នាំ២០១៩ ទៅដល់ ៩៥% ក្នុងឆ្នាំ២០២៩។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

សូចនាករសេដ្ឋកិច្ចសំខាន់ៗ នឹងចេញផ្សាយក្នុងសប្តាហ៍ខាងមុខ នៅក្នុងប្រទេសវៀតណាម កូរ៉េខាងត្បូង ជប៉ុន និងថៃ។ ធនាគារកណ្តាលរបស់ប្រទេសកូរ៉េខាងត្បូង នឹងធ្វើការប្រកាសទៅលើការសម្រេចអត្រាការប្រាក់នៅថ្ងៃសុក្រ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី២៦ ខែសីហា ឆ្នាំ២០១៩</u>

- ផលិតកម្មឧស្សាហកម្មរបស់សឹង្ហបុរី ខែកក្កដា
- សន្ទស្សន៍សេដ្ឋកិច្ចនាំមុខរបស់ជប៉ុន ខែមិថុនា
- តុល្យភាពពាណិជ្ជកម្មរបស់ទីក្រុងហុងកុង ខែកក្កដា

<u>ថ្ងៃអង្គារ ទី២៧ ខែសីហា ឆ្នាំ២០១៩</u>

- សន្ទស្សន៍ជំនឿទុកចិត្តអ្នកប្រើប្រាស់របស់កូរ៉េខាងត្បូង ខែសីហា
- ផលិតកម្មឧស្សាហកម្មរបស់ថៃ ខែកក្កដា
- វិនិយោគផ្ទាល់បរទេសរបស់វៀតណាម ខែសីហា

<u>ថ្ងៃពុធ ទី២៨ ខែសីហា ឆ្នាំ២០១៩</u>

- តុល្យភាពពាណិជ្ជកម្មរបស់ប្រ៊ុយណេ ខែឧសភា
- កំណើនប្រាក់កម្ចីនៅតំបន់អឺរ៉ុប ខែកក្កដា

<u>ថ្ងៃព្រហស្បតិ៍ ទី២៩ ខែសីហា ឆ្នាំ២០១៩</u>

- សន្ទស្សន៍ជំនឿទុកចិត្តលើធុរៈកិច្ចនៅកូរ៉េខាងត្បូង ខែសីហា
- តុល្យភាពពាណិជ្ជកម្មរបស់វៀតណាម ខែសីហា
- អត្រាអតិផរណារបស់វៀតណាម ខែសីហា
- ផលិតកម្មឧស្សាហកម្មរបស់វៀតណាម ខែសីហា
- ទិន្នន័យការមកដល់របស់អ្នកទេសចរណ៍នៅវៀតណាម ខែសីហា

<u>ថ្ងៃសុក្រ ទី៣០ ខែសីហា ឆ្នាំ២០១៩</u>

- ផលិតកម្មឧស្សាហកម្មរបស់កូរ៉េខាងត្បូង ខែកក្កដា
- ទិន្នន័យការលក់រាយនៅកូរ៉េខាងត្បូង ខែកក្កដា
- អត្រានិកម្មភាពរបស់ជប៉ុន ខែកក្កដា
- អត្រាអតិផរណារបស់ជប៉ុន ខែកក្កដា
- ផលិតកម្មឧស្សាហកម្មរបស់ជប៉ុន ខែកក្កដា
- ការសម្រេចលើអត្រាការប្រាក់របស់កូរ៉េខាងត្បូង
- គណនីចរន្តរបស់ថៃ ខែកក្កដា